# លក្ខន្តិកៈប្រតិបត្តិការ និងគណនីប្រាក់បញ្ញើ
# Transaction and Deposit Accounts

មានសុពលភាពចាប់ពីថ្ងៃទី 15 ខែ កញ្ញា ឆ្នាំ 2008

Effective date: 15 September 2008

ធនាគារ ANZ Royal

ឯកសារនេះរួមបញ្ចូលនូវលក្ខខណ្ឌ

សម្រាប់ប្រភេទគណនីដូចខាងក្រោមនេះ៖

គណនី Access Account

គណនី Premier

គណនីប្រាក់សន្សំ

គណនីគ្រប់គ្រងសាច់ប្រាក់-ផ្ទាល់ខ្លួន

សេវាកម្មបើកប្រាក់ខែដល់បុគ្គលិក

គណនីមូលប្បទានបត្រពាណិជ្ជកម្ម

គណនីមូលប្បទានបត្រពាណិជ្ជកម្ម (មានការប្រាក់)

គណនីគ្រប់គ្រងសាច់ប្រាក់-ជំនួញ

គណនីរូបិយប័ណ្ណបរទេស

គណនីប្រាក់បញ្ញើមានកាលកំណត់

ឯកសារនេះត្រូវអានជាមួយកូនសៀវភៅនិយាយពី

ការគិតកម្រៃ និងថ្លៃឈ្នួលរបស់ធនាគារ ANZ Royal ។ ឯកសារទាំង

ពីរនេះបង្កើតបានជាលក្ខខណ្ឌ ដែលត្រូវយក

មកអនុវត្តជាមួយផលិតផលខាងលើ។

## 1. លក្ខខណ្ឌផ្សេងៗទាក់ទងនឹងធនាគារ ANZ Royal

នៅក្នុងលក្ខខណ្ឌនេះ៖

- ធនាគារ ANZ Royal មានន័យថា ធនាគារ អេ អិន ហ្សេត រ៉ូយ៉ាល់ កម្ពុជា។
- គណនីមានន័យថា គណនីដែលត្រូវបានយកមកអនុវត្តតាមលក្ខខណ្ឌទាំងនេះ គណនីរួមមានដូចដែលបញ្ជាក់នៅលើក្របខាងមុខនៃកូនសៀវភៅនេះ។
- ម្ចាស់គណនីមានន័យថា បុគ្គលម្នាក់ ឬច្រើនគ្នាដែលបើកគណនីដោយប្រើឈ្មោះរបស់ខ្លួន និងទទួលខុសត្រូវចំពោះគណនីតាមរយៈហត្ថលេខា ឬគល់សិទ្ធិ។ ប្រសិនបើគណនីមានម្ចាស់ច្រើន ម្ចាស់គណនីទាំងអស់ត្រូវទួលខុសត្រូវរួមគ្នា និងទទួលជាបុគ្គលរៀងៗខ្លួន។
- កាតឥណពន្ធធនាគារ ANZ Royal មានន័យថាកាតឥណពន្ធអន្តរជាតិ ឬកាតឥណពន្ធ Premier ដែលធនាគារ ANZ Royal ចេញជូនឱ្យលោកអ្នក ហើយលោកអ្នកអាចប្រើដើម្បីធ្វើប្រតិបត្តិការគណនីធនាគារ ANZ Royal នៅម៉ាស៊ីនអេឡិចត្រូនិកទាំងនៅក្នុងប្រទេសកម្ពុជា និង/ឬនៅបរទេស។

## 2. ការអនុវត្តចំពោះលក្ខខណ្ឌទាំងនេះ

លក្ខខណ្ឌទាំងនេះនឹងត្រូវយកមកអនុវត្តភ្លាមចំពោះគណនីនីមួយៗដែលលោកអ្នកបានបើកជាមួយនឹងធនាគារ ANZ Royal ។ លក្ខខណ្ឌទាំងនេះត្រូវយកមកអនុវត្តចំពោះលោកអ្នក និងអ្នកស្នងមរតកស្របច្បាប់របស់លោកអ្នក ឬអ្នកទទួលមរតកដែលមានការទទួលស្គាល់ស្របច្បាប់។ លក្ខខណ្ឌទាំងនេះត្រូវបានអនុវត្តស្របច្បាប់តាមលក្ខខណ្ឌផ្សេងៗទៀតដែលអាចយកមកអនុវត្តសម្រាប់ប្រតិបត្តិការជាក់លាក់ ឬសេវាកម្មទាក់ទងនឹងគណនីរបស់លោកអ្នក (លក្ខខណ្ឌជាក់លាក់)។ ប្រសិនបើមិនមានចែងផ្ទុយពីលក្ខខណ្ឌជាក់លាក់ទេ បើមានភាពមិនចុះសម្រុងគ្នារវាងលក្ខខណ្ឌទាំងនេះ និងលក្ខខណ្ឌជាក់លាក់ លក្ខខណ្ឌទាំងនេះនឹងត្រូវយកមកអនុវត្ត។

លក្ខខណ្ឌទាំងនេះអាចត្រូវបានកែប្រែម្តងម្កាលតាមរយៈការព្រមព្រៀងជាមួយធនាគារ ANZ Royal ឬដោយការជូនដំណឹងដែលធ្វើឡើងដោយធនាគារ ANZ Royal ក្រោមខទី 8 ។

## 3. សិទ្ធិក្នុងការធ្វើប្រតិបត្តិការគណនី

នៅពេលដែលលោកអ្នកបើកគណនី លោកអ្នកត្រូវតែងតាំងមនុស្សដែលមានសិទ្ធិក្នុងការធ្វើប្រតិបត្តិការគណនី។ ប្រសិនបើលោកអ្នកមានបំណងចង់ប្តូរមនុស្សដែលមានសិទ្ធិក្នុងការធ្វើប្រតិបត្តិការចំពោះគណនីលោកអ្នកត្រូវតែជូនព័ត៌មានមកធនាគារ ANZ Royal ជាលាយលក្ខអក្សរ។ លើកលែងតែក្នុងករណីដែលមានការព្រមព្រៀងគ្នាច្បាស់លាស់ បើពុំដូច្នោះទេធនាគារ ANZ Royal អាចអនុវត្តបានគ្រប់ពេលវេលាទាំងអស់ដោយផ្អែកលើអ្នកមានសិទ្ធិធ្វើប្រតិបត្តិការម្នាក់ ឬច្រើននាក់ដែលត្រូវបានប្រគល់សិទ្ធិដោយលោកអ្នកដែលមានសិទ្ធិពេញលេញក្នុងការធ្វើកិច្ចការ ឬដោះ-ស្រាយបញ្ហា និងប្រតិបត្តិការគ្រប់បែបយ៉ាងទាក់ទងទៅនឹងគណនី (រួមទាំងការដកប្រាក់ផងដែរ)។

លោកអ្នកត្រូវទទួលខុសត្រូវលើរាល់កិច្ចការ និងប្រតិបត្តិការទាំងអស់នៃគណនី។ ប្រសិនបើលោកអ្នកជាម្ចាស់គណនីរួមគ្នាជាមួយនឹងមនុស្សម្នាក់ទៀត ឬមនុស្សច្រើននាក់ផ្សេងទៀត ដូច្នេះលោកអ្នកត្រូវទទួលខុសត្រូវរួមគ្នា ឬតាំងអស់គ្នាលើរាល់ការប្រព្រឹត្តិទៅនៃប្រតិបត្តិការទាំងអស់ទាក់ទងនឹងគណនី។

## 4. ថ្លៃឈ្នួល កម្រៃ និងការប្រាក់

រាល់គណនីទាំងអស់ត្រូវមានគណនីជាក់លាក់ទាក់ទងទៅនឹងថ្លៃឈ្នួល និងកម្រៃដែលបានបញ្ជាក់ច្បាស់លាស់ក្នុងកូនសៀវភៅដែលនិយាយពីកម្រៃ និងថ្លៃឈ្នួលរបស់ធនាគារ ANZ Royal ដែលមានការកែប្រែម្តងម្កាល។

លោកអ្នកយល់ព្រមថាបង់ថ្លៃឈ្នួល និងកម្រៃផ្សេងៗផ្ទាល់ចេញពីគណនី

របស់លោកអ្នក។ ធនាគារ ANZ Royal នឹងបង់ការប្រាក់ផ្អែកលើចំនួនទឹកប្រាក់ដែលមានក្នុងគណនីរបស់លោកអ្នកក្នុងអត្រាមួយដែលបានជូនដំណឹងទៅលោកអ្នក (ស្របតាម ខទី 8) ហើយស្របតាមបែបបទស្តង់ដារផងដែរ។

## 5. *របាយការណ៍គណនី និងឯកសារឆ្លើយឆ្លង*

របាយការណ៍គណនីនឹងផ្តល់ជូនសម្រាប់គ្រប់គណនីទាំងអស់លើកលែងតែគណនីប្រាក់បញ្ញើមានកាលកំណត់។ របាយការណ៍គណនីសម្រាប់ប្រាក់បញ្ញើមានកាលកំណត់នឹងប្រគល់ជូននៅពេលដែលគណនីដល់ពេលកំណត់ប៉ុណ្ណោះ។ លោកអ្នកអាចសរសេរជាលាយលក្ខ័អក្សរដើម្បីស្នើសុំរបាយការណ៍គណនីរបស់លោកអ្នក ហើយរាល់សេចក្តីជូនដំណឹងឯកសារឆ្លើយឆ្លងគ្នា ឬឯកសារផ្សេងៗទៀតដែលបានចេញឱ្យដោយធនាគារ ANZ Royal ទាក់ទងទៅនឹងគណនីរបស់លោកអ្នកនឹងត្រូវផ្តល់ជូនតាមរបៀបដូចខាងក្រោមនេះ ÷

(ក) លោកអ្នកនឹងទទួលឯកសារទាំងនេះពីសាខាធនាគារ ANZ Royal ដល់លោកអ្នកបានបើកគណនីនៅទីនោះ ឬ

(ខ) ធនាគារ ANZ Royal នឹងផ្ញើតាមសំបុត្រ ផ្ញើតាមទូរសារ ឬតាមអ៊ីមែល (តាមការចង់បានរបស់លោកអ្នក)។ លោកអ្នកនឹងទទួលឯកសារទាំងនោះនៅថ្ងៃធ្វើការបន្ទាប់ ក្រោយពីឯកសារទាំងនោះត្រូវបានផ្ញើចេញ។

## 6. *គណនីរួម*

នៅពេលដែលគណនីរបស់លោកអ្នកមានម្ចាស់រួមគ្នាជាមួយនឹងមនុស្សម្នាក់ទៀត ឬច្រើននាក់ផ្សេងទៀត ចំណុចខាងក្រោមនេះត្រូវយកមកអនុវត្ត :

(ក) ធនាគារ ANZ Royal អាចផ្តល់របាយការណ៍គណនី សេចក្តីជូនដំណឹង ឯកសារឆ្លើយឆ្លងគ្នា និងឯកសារផ្សេងៗទៀតទៅឱ្យបុគ្គលណាម្នាក់ដែលជាម្ចាស់គណនី (តាមរយៈការមកយកពីសាខាធនាគារ ANZ Royal ឬតាមការផ្ញើជូនលោកអ្នកតាមសំបុត្រ

ទូរសារ ឬតាមអ៊ីមែល)

(ខ) ប្រសិនបើធនាគារ ANZ Royal ផ្តល់របាយការណ៍គណនី សេចក្តីជូនដំណឹង ឯកសារឆ្លើយឆ្លងគ្នា និងឯកសារផ្សេងៗទៀតជូនបុគ្គលម្នាក់ដែលជាម្ចាស់គណនី ឯកសារទាំងនោះនឹងត្រូវបានចាត់ទុកថាបានប្រគល់ទៅឱ្យគ្រប់ម្ចាស់គណនីទាំងអស់ហើយ

(គ) ប្រសិនបើម្ចាស់គណនីណាមួយស្លាប់ ធនាគារ ANZ Royal នឹងចាត់ទុកតុល្យភាពថាមានម្ចាស់រួមគ្នា ដោយម្ចាស់គណនីដែលនៅរស់និងអ្នកទទួលមរតក ស្របច្បាប់នៃម្ចាស់គណនីដែលបានស្លាប់ លើកលែងតែច្បាប់តម្រូវឱ្យ ឬអនុញ្ញាតឱ្យធនាគារ ANZ Royal ធ្វើអ្វីផ្សេងពីនេះ។ ប្រសិនបើអ្នកទទួលមរតក គឺជាមនុស្សតែមួយជាមួយនឹងម្ចាស់គណនីដែលនៅរស់ នោះម្ចាស់គណនីដែលនៅរស់នឹងក្លាយជាម្ចាស់គណនីតែម្នាក់គត់។

## 7. មូលប្បទានប័ត្រ និងមូលនិធិដែលបានផ្ទៀងផ្ទាត់រួច

ប្រាក់បញ្ញើមិនមែនសាច់ប្រាក់ (ដូចជាមូលប្បទានប័ត្រ និងប្រាក់បញ្ញើមិនទាន់ទូទាត់រួចផ្សេងទៀត) នឹងមិនត្រូវបានដាក់បញ្ចូលទៅក្នុងគណនីរបស់លោកអ្នករហូតដល់មានការផ្ទៀងផ្ទាត់រួចរាល់ ហើយត្រូវធ្វើប្រតិបត្តិការដូចខាងក្រោមនេះ៖

នៅពេលដែលលោកអ្នកបង់មូលប្បទានប័ត្រចូលទៅក្នុងគណនីលោកអ្នកធនាគារ ANZ Royal តាមឆន្ទានុសិទ្ធិរបស់ខ្លួន អនុញ្ញាតឱ្យលោកអ្នកចុះហត្ថលេខាលើមូលប្បទានប័ត្រមុនពេលធ្វើការផ្ទៀងផ្ទាត់ហើយអាចតម្រូវឱ្យលោកអ្នកបង់សោហ៊ុយប្រតិបត្តិការទៅលើមូលនិធិដែលមិនទាន់បានផ្ទៀងផ្ទាត់រួច។ ប្រសិនបើមិនអាចផ្ទៀងផ្ទាត់បានទេប្រាក់បញ្ញើនឹងត្រូវដកចេញពីគណនីរបស់លោកអ្នក ទោះបីប្រាក់បញ្ញើនោះត្រូវបានបញ្ចូលទៅក្នុងគណនីក៏ដោយ ហើយធនាគារ ANZ Royal អាចតម្រូវឱ្យលោកអ្នកបង់ថ្លៃពិន័យ។

លោកអ្នកត្រូវតែជូនព័ត៌មានមកធនាគារ ANZ Royal ឱ្យបានឆាប់តាម

លទ្ធភាពដែលអាចធ្វើទៅបានប្រសិនបើលោកអ្នកសង្ស័យ ឬដឹងថា សៀវភៅមូលប្បទានប័ត្ររបស់លោកអ្នកត្រូវបានបាត់បង់ ឬត្រូវបានលួច។ លោកអ្នកត្រូវទទួលខុសត្រូវចំពោះប្រតិបត្តិការទាំងឡាយណាដែលកើតឡើងដោយសារភាពយឺតយ៉ាវរបស់លោកអ្នកក្នុងការជូនព័ត៌មានមកកាន់ធនាគារ ANZ Royal ទោះបីប្រតិបត្តិការទាំងនោះបានធ្វើឡើងដោយគ្មានការអនុញ្ញាតពីលោកអ្នកយ៉ាងណាក៏ដោយ។

## 8. *ការកែប្រែកម្រៃ ថ្លៃឈ្នួល អត្រាការប្រាក់ និងលក្ខខណ្ឌ*

លោកអ្នកយល់ព្រមថា ៖

(ក) គ្រប់ពេលទាំងអស់ធនាគារ ANZ Royal តាមឆន្ទានុសិទ្ធិរបស់ខ្លួនអាចធ្វើការកែប្រែលក្ខខណ្ឌថ្លៃឈ្នួល កម្រៃផ្សេងៗ និងអត្រាការប្រាក់ទាំងអស់នេះ ដែលអនុវត្តចំពោះគណនីរបស់លោកអ្នក និង

(ខ) រាល់ការកែប្រែលើលក្ខខណ្ឌ ថ្លៃឈ្នួល កម្រៃ និងអត្រាការប្រាក់ទាំងនេះដែលអនុវត្តចំពោះគណនីរបស់លោកអ្នកនឹងត្រូវយកមកអនុវត្តភ្លាមៗបន្ទាប់ពីលោកអ្នកបានទទួលសេចក្តីជូនដំណឹងស្តីពីការកែប្រែទាំងនោះ ឬក្រោមខទី 8 នេះ។

លោកអ្នកយល់ព្រមថាធនាគារ ANZ Royal អាចជូនដំណឹងដល់លោកអ្នកអំពីការកែប្រែផ្សេងៗចំពោះថ្លៃឈ្នួល កម្រៃ និងកម្រៃអត្រាការប្រាក់ ឬលក្ខខណ្ឌទាំងនេះនៃគណនីរបស់លោកអ្នក ដោយសេចក្តីជូនដំណឹងដែលត្រូវបង្ហាញជូនដូចខាងក្រោមនេះ ៖

(ក) នៅតាមសាខាធនាគាររបស់យើងខ្ញុំ

(ខ) នៅលើគេហទំព័ររបស់យើងខ្ញុំ

(គ) ដោយផ្សព្វផ្សាយតាមកាសែតសំខាន់ៗប្រចាំថ្ងៃ ឬកាសែតក្នុងស្រុកផ្សេងៗទៀតក្រោយពីការបិទប្រកាសព័ត៌មាន និងការផ្សព្វផ្សាយព័ត៌មានទាំងនេះ លោកអ្នកត្រូវបានសន្មត់ថាបានទទួលព័ត៌មានទាំងនេះជាស្វ័យប្រវត្តិ។

## 9. ការទទួលខុសត្រូវរបស់លោកអ្នកចំពោះប្រតិបត្តិការដែលគ្មានការអនុញ្ញាត

លោកអ្នកត្រូវទទួលខុសត្រូវលើគ្រប់ប្រតិបត្តិការទាំងអស់ដែលកើតឡើងដោយសារការប្រើឈ្មោះសម្ងាត់ លេខសម្ងាត់ លេខកូដ ដែលផ្តល់ជូនសម្រាប់ប្រើជាមួយនឹងគណនីរបស់លោកអ្នក (ប្រតិបត្តិការអេឡិចត្រូនិក)

ចំពោះប្រតិបត្តិការផ្សេងៗទៀត (មិនមែនជាប្រតិបត្តិការអេឡិចត្រូនិក) លោកអ្នកត្រូវទទួលខុសត្រូវចំពោះគណនីរបស់លោកអ្នកដូចខាងក្រោមនេះ ៖

(ក) លោកអ្នកត្រូវពិនិត្យឡើងវិញ និងផ្ទៀងផ្ទាត់ព័ត៌មានផ្សេងៗទាក់ទងនឹងគណនីដែលបានបើកជាមួយនឹងធនាគារ ANZ Royal ក្នុងរយៈពេល 30 ថ្ងៃ ក្រោយពេលចុងខែនីមួយៗ (រយៈពេលផ្ទៀងផ្ទាត់គណនី) ហើយត្រូវជូនព័ត៌មានភ្លាមៗមកធនាគារ ANZ Royal ប្រសិនបើ ៖

1/ មានការសង្ស័យថា បានកោស លុប ឬបានកត់ត្រាខុសទាក់ទងនឹងគណនី ឬ

2/ រាល់ប្រតិបត្តិការដែលមិនមានការអនុញ្ញាត ត្រូវបានធ្វើឡើងចំពោះគណនី

(ខ) លើកលែងតែក្នុងករណីដែល

1/ លោកអ្នកជូនព័ត៌មានមកធនាគារ ANZ Royal ស្របតាមអនុប្រយោគ (ក)

2/ មានការកត់ត្រានូវកម្រៃសេវាដែលធ្វើឡើងដោយធនាគារ ANZ Royal ឬ

3/ ធ្វើឱ្យខាតបង់ប្រយោជន៍របស់លោកអ្នកដែលបង្កឡើងដោយភាពមិនស្មោះត្រង់របស់បុគ្គលិកធនាគារ ANZ Royal ឬភ្នាក់ងារ ឬក្រុមហ៊ុនពាក់ព័ន្ធជាមួយនឹងធនាគារ ANZ Royal ឬពាណិជ្ជករ ឬភ្នាក់ងាររបស់ពាណិជ្ជករនោះ ឬបុគ្គលិករបស់ពាណិជ្ជករនោះ។

ធនាគារ ANZ Royal មានសិទ្ធិផ្តាច់មុខបន្ទាប់ពីផ្ទៀងផ្ទាត់រួចក្នុងការចាត់ទុកថារាល់កំណត់ត្រាទាំងអស់ដែលមាននៅក្នុងរបាយការណ៍គណនីទាក់ទងនឹងប្រតិបត្តិការមិនមែនតាមប្រព័ន្ធអេឡិចត្រូនិកថាជាភស្តុតាងជាក់លាក់ដោយមិនចាំបាច់ត្រូវការភស្តុតាងអ្វីបន្ថែមទៀតដើម្បីបញ្ជាក់ថាកំណត់ត្រាទាំងនោះត្រឹមត្រូវ និងគ្រប់គ្រាន់នោះឡើយ ហើយធនាគារ ANZ Royal ត្រូវរួចផុតពីការទាមទារណាទាំងអស់នឹងចំនួនទាំងនេះ។

(គ) លោកអ្នកត្រូវតែយកចិត្តទុកដាក់ និងមានការប្រុងប្រយ័ត្នឱ្យបានសមស្របដើម្បីការពារកុំឱ្យមានប្រតិបត្តិការមិនមានការអនុញ្ញាត ឬមានការលួចក្លែងបន្លំកើតឡើងចំពោះគណនីរបស់លោកអ្នករួមមានចំណុចសំខាន់មួយចំនួនដូចខាងក្រោម ៖

1/ ប្រព័ន្ធ និងបែបបទនៃការផ្ទៀងផ្ទាត់ ដែលធ្វើឱ្យលោកអ្នកអាចកំណត់បានភ្លាមៗថាតើចំនួនទឹកប្រាក់ដែលមិនមានការអនុញ្ញាតត្រូវបានដកចេញពីគណនីរបស់លោកអ្នក ឬយ៉ាងណា

2/ ការបញ្ជាក់ទ្បៀងទាត់ពីប្រតិបត្តិការលើគណនីរបស់លោកអ្នកដោយមនុស្សដែលមានសមត្ថភាព ឬមានបទពិសោធន៍គ្រប់គ្រាន់ល្មម

3/ ប្រសិនបើមិនមានការលំបាកក្នុងការអនុវត្តទេ ការបែងចែកភារកិច្ចសមស្រប គឺថាមនុស្សដែលទទួលខុសត្រូវចំពោះបញ្ហាដែលបានពិពណ៌នានៅក្នុងអនុប្រយោគ (ក) និង (គ) គឺជាមនុស្សដែលមិនមែនជាអ្នកទទួលលើការសរសេរ ឬការអនុញ្ញាតចំពោះប្រតិបត្តិការ។

ប្រសិនបើលោកអ្នកមិនធ្វើតាមការណែនាំខាងលើនេះទេ មានន័យថាលោកអ្នកទទួលយល់ព្រមថា លោកអ្នកគ្មានសិទ្ធិក្នុងការទាមទារអ្វីពីធនាគារទាក់ទងទៅនឹងការធ្វើប្រតិបត្តិការ មិនមែនតាមប្រព័ន្ធអេឡិចត្រូនិកដែលគ្មានការអនុញ្ញាត ឬដោយមានការលួចបន្លំ។

## 10. ការរក្សាការសម្ងាត់

ធនាគារ ANZ Royal នឹងមិនប្រកាសពីព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក គណនីលម្អិត ឬប្រតិបត្តិការគណនីប្រាប់បុគ្គលណាម្នាក់នោះទេ។ ប្រធានបទមានដូចខាងក្រោមនេះ ៖

លោកអ្នកយល់ព្រមថា ធនាគារ ANZ Royal អាចប្រាប់ព័ត៌មានទៅធនាគារ Australia and New Zealand Banking Group Limited ឬសាខារបស់ខ្លួនក្នុងគោលបំណងរៀបចំទិន្នន័យ និងកិច្ចការផ្សេងៗទៀតដែលមានការពាក់ព័ន្ធ អ្នកផ្គត់ផ្គង់សេវាកម្មដែលមានទំនាក់ទំនងជាមួយនឹងធនាគារ ANZ Royal ដើម្បីអនុវត្ត ឬជួយការងារ ឬសកម្មភាពផ្សេងៗរបស់ធនាគារ ឬនៅពេលដែលច្បាប់តម្រូវឱ្យបង្ហាញប្រាប់ព័ត៌មានទៅមនុស្សម្នាក់ទៀត។

លោកអ្នកយល់ព្រមថាធនាគារ ANZ Royal អាចបង្ហាញព័ត៌មានផ្ទាល់ខ្លួនរបស់លោកអ្នក (ប៉ុន្តែមិនមានព័ត៌មានលម្អិតនៃគណនីរបស់លោកអ្នក ឬការធ្វើប្រតិបត្តិនៃគណនីរបស់លោកអ្នកទេ) ទៅឱ្យអង្គភាពណាមួយដែលមានទំនាក់ទំនងជាមួយនឹងធនាគារ ANZ Royal ក្នុងគោលបំណងផ្សព្វផ្សាយ ឬផ្តល់ទៅឱ្យអ្នកផ្តល់សេវាកម្មណាមួយ ដែលធនាគារ ANZ Royal បានព្រមព្រៀងគ្នាក្នុងការធ្វើការស្ទង់មតិអតិថិជន ឬសម្រាប់ការស្រាវជ្រាវពីអតិថិជន និងការស្វែងយល់ពីទីផ្សារ ។ លោកអ្នកយល់ព្រមថាអ្នកផ្តល់សេវាកម្មរបស់ធនាគារ ANZ Royal អាចធ្វើការទាក់ទងជាមួយលោកអ្នកក្នុងគោលបំណងនោះ។

ធនាគារនឹងបង្ហាញព័ត៌មានដែលទាក់ទងនឹងអតិថិជនរបស់ខ្លួនលុះត្រាតែធនាគារមានជំនឿដោយផ្អែកលើមូលដ្ឋានសមរម្យថាអ្នកទទួលព័ត៌មានរក្សាការសម្ងាត់ ដូចធនាគារ ANZ Royal ដែរ។

លោកអ្នកយល់ព្រមថារាល់ការផ្តល់ព័ត៌មានក្នុងករណីដូចបានរៀបរាប់ខាងលើដោយធនាគារ ANZ Royal ឬនាយករដ្ឋមន្ត្រី អ្នកចាត់ចែងបុគ្គលិក ឬមនុស្សផ្សេងទៀត នឹងចាត់ទុកថា ជាការរំលោភលើច្បាប់ ឬ

កាតព្វកិច្ចភាពសម្ងាត់នៃវិជ្ជាជីវៈនោះឡើយ។

## 11. ការរំខានចំពោះសេវា

លោកអ្នកយល់ព្រមថា ធនាគារ ANZ Royal នឹងមិនទទួលខុសត្រូវចំពោះការខូចខាតដែលបានកើតឡើងដោយសារសេវាកម្មមិនអាចប្រើប្រាស់បានជាបណ្តោះអាសន្ន ឬនៅពេលប្រព័ន្ធ ឬឧបករណ៍មិនដំណើរការជាប្រក្រតី។

## 12. ការផ្តល់ឥណទាន

ក្នុងករណីដែលមិនមានកិច្ចព្រមព្រៀងជាក់លាក់ក្នុងការផ្តល់ឥណទានទាក់ទងនឹងគណនីរបស់លោកអ្នក (ឧ. តាមរយៈឥណទានលើសសមតុល្យ)

ប្រសិនបើលោកអ្នកស្នើសុំដកប្រាក់ ឬទូទាត់ប្រាក់ចេញពីគណនីរបស់លោកអ្នកដែលលើសពីចំនួនដែលមានក្នុងគណនីរបស់លោកអ្នក ធនាគារ ANZ Royal តាមឆន្ទានុសិទ្ធិរបស់ខ្លួនអាចអនុញ្ញាតឱ្យដកប្រាក់បានតាមលក្ខខ័ណ្ឌដូចខាងក្រោម ៖

(ក) លោកអ្នកត្រូវបង់ប្រាក់ក្នុងអត្រា Singapore Interbank (SIBOR) បូកបន្ថែម 20% ទៀត គិតទៅលើចំនួនទឹកប្រាក់ដែលបានដកលើស។

(ខ) ក្នុងករណីដែលធនាគារយល់ព្រមឱ្យមានការដកប្រាក់លើសសមតុល្យដែលមានក្នុងគណនី លោកអ្នកត្រូវបង់កម្រៃសេវាកម្មតាមការកំណត់របស់ធនាគារ (សូមមើលសេចក្តីលម្អិតនៅក្នុងកូនសៀវភៅដែលនិយាយថ្លៃឈ្នួល និងកម្រៃរបស់ធនាគារ ANZ Royal)។

(គ) ធនាគារនឹងដកប្រាក់ និងកម្រៃសេវាកម្មផ្សេងៗ ដែលពាក់ព័ន្ធនឹងការដកលើសនេះ ចេញពីគណនីរបស់លោកអ្នក។

(ឃ) លោកអ្នកត្រូវបង់ប្រាក់សងវិញនូវចំនួនដែលដកលើស ព្រមទាំងការប្រាក់ និងកម្រៃផ្សេងៗ ក្នុងរយៈពេល 7 ថ្ងៃ។

## 13. ការប្រឆាំងការលាងលុយកខ្វក់

លោកអ្នកយល់ព្រមថា ធនាគារ ANZ Royal អាចពន្យារពេល ឬបដិសេធមិនធ្វើប្រតិបត្តិការណាមួយដោយមិនទទួលខុសត្រូវអ្វីទាំងអស់ ប្រសិនបើធនាគារជឿជាក់ថាមានហេតុផលសមរម្យដែលថា៖

(ក) ប្រតិបត្តិការអាចរំលោភលើច្បាប់ណាមួយនៅក្នុងប្រទេសកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត ឬ

(ខ) ប្រតិបត្តិការអាចទាក់ទងដោយផ្ទាល់ ឬដោយប្រយោលទៅនឹងមូលនិធិដែលទទួលបានដោយខុសច្បាប់ ឬ

(គ) លោកអ្នកយល់ព្រមថាការផ្តល់ព័ត៌មានទាំងអស់មកឱ្យធនាគារដែលធនាគារតម្រូវឱ្យអនុវត្តតាមច្បាប់ទាំងអស់នៅក្នុងប្រទេសកម្ពុជា ឬប្រទេសណាមួយផ្សេងទៀត។

លោកអ្នកយល់ព្រមថាធនាគារអាចបង្ហាញព័ត៌មានលោកអ្នក ឬធ្វើរបាយការណ៍ទៅកាន់ភ្នាក់ងារអនុវត្តច្បាប់ ឬនិយ័តករដើម្បីអនុវត្តតាមច្បាប់ទាំងអស់នៅក្នុងប្រទេសកម្ពុជា ឬប្រទេសផ្សេងទៀត។

បើលោកអ្នកមិនបានប្រាប់ថា លោកអ្នកធ្វើឡើងក្នុងនាមភាគីមួយផ្សេងទៀត នោះទើបលោកអ្នកធានាអះអាងថាលោកអ្នក និងអ្នកតំណាងដែលមានសិទ្ធិរបស់លោកអ្នកបានធ្វើអ្វីៗជំនួយឱ្យលោកអ្នក ក្នុងការបើកគណនី ក្នុងការចុះកិច្ចព្រមព្រៀង និងការធ្វើប្រតិបត្តិអ្វីផ្សេងទៀតចំពោះគណនីរបស់លោកអ្នក។

លោកអ្នកយល់ព្រមទទួលខុសត្រូវចំពោះធនាគារ ANZ Royal ថារាល់ការទូទាត់ប្រាក់ទាំងអស់ដែលធនាគារ ANZ Royal បានធ្វើស្របតាមការណែនាំរបស់លោកអ្នកនឹងមិនរំលោភលើច្បាប់ណាមួយរបស់ប្រទេសកម្ពុជា ឬច្បាប់របស់ប្រទេសណាមួយផ្សេងទៀតទេ។

## 14. ការប្តូរឈ្មោះ និងអាសយដ្ឋានដោយហត្ថលេខី

ធនាគារ ANZ Royal នឹងមិនទទួលខុសត្រូវចំពោះកំហុស ឬការបាត់

បង់ណាមួយដែលទាក់ទងទៅនឹងការផ្លាស់ប្តូរខុសព័ត៌មានលម្អិតនៃគណនីរបស់លោកអ្នក ប្រសិនធនាគារ ANZ Royal មិនបានទទួលសេចក្តីជូនដំណឹងជាមុននោះទេ។

## 15. សិទ្ធិរបស់ធនាគារ ANZ Royal ក្នុងការបញ្ចូលគណនីចូលជាគណនីតែមួយ

ធនាគារ ANZ Royal អាចដាក់បញ្ចូលសមតុល្យទឹកប្រាក់នៃគណនីរបស់អ្នកដែលមានចំនួនចាប់ពីពីរ ឬច្រើនជាងពីរគណនីមកជាគណនីតែមួយ ទោះបីជាគណនីនោះត្រូវបានបើកនៅតាមសាខាក្រោមរូបិយប័ណ្ណផ្សេងគ្នាក៏ដោយ។ ករណីនេះអាចកើតឡើង នៅពេលដែលលោកអ្នកដកប្រាក់លើសពីសមតុល្យដែលលោកអ្នកមាន ឬនៅពេលដែលគណនីណាមួយមានសមតុល្យអវិជ្ជមាន ហើយគណនីផ្សេងទៀតមានសមតុល្យវិជ្ជមាន មានន័យថាសមតុល្យគណនីមួយអាចត្រូវបានយកទៅប្រើប្រាស់បង់សងសមតុល្យគណនីមួយទៀតដែលបានបើកក្នុងធនាគារ ANZ Royal ។

ប្រសិនបើធនាគារ ANZ Royal ជ្រើសរើសដាក់បញ្ចូលគណនីរបស់លោកអ្នកដែលបានបើកក្រោមរូបិយប័ណ្ណផ្សេងគ្នា ធនាគារនឹងជ្រើសរើសយករូបិយប័ណ្ណមួយតាមអត្រាប្តូរប្រាក់លក្ខណៈស្តង់ដារ។ ធនាគារ ANZ Royal នឹងផ្តល់ព័ត៌មានជូនលោកអ្នកភ្លាមប្រសិនបើគណនីលោកអ្នកត្រូវបានដាក់បញ្ចូលគ្នា។ ធនាគារនឹងមិនផ្តល់ព័ត៌មានជូនលោកអ្នកជាមុនទេ ហើយលោកអ្នកមិនគួរសន្មតថា គណនីរបស់លោកអ្នកត្រូវបានដាក់បញ្ចូលគ្នាទេ លុះត្រាតែធនាគារ ANZ Royal យល់ព្រមការរៀបចំនេះ។

## 16. រូបិយប័ណ្ណ

លើកលែងតែធនាគារយល់ព្រមអ្វីផ្សេងពីនោះ រាល់ការទូទាត់ប្រាក់ទាំងអស់ដែលបានធ្វើឡើងក្រោម ឬស្របតាមកិច្ចព្រមព្រៀងនេះ ត្រូវធ្វើឡើងជារូបិយប័ណ្ណដែលលោកអ្នកជ្រើសរើសយកសម្រាប់គណនីរបស់លោកអ្នក។

ប្រសិនបើគណនីណាមួយរបស់លោកអ្នកត្រូវប្រើរូបិយប័ណ្ណដុល្លារសហរដ្ឋអាមេរិក ហើយច្បាប់បទបញ្ញត្តិ ឬគោលការណ៍ណែនាំចាំបាច់របស់រាជរដ្ឋាភិបាលកម្ពុជាតម្រូវដោយផ្ទាល់ ឬដោយប្រយោលឱ្យធនាគារ ANZ Royal ផ្ទេរគណនីដែលប្រើដុល្លារអាមេរិកឱ្យទៅជាគណនីដែលប្រើរូបិយប័ណ្ណខ្មែរ ឬរូបិយប័ណ្ណអ្វីផ្សេងទៀត ធនាគារ ANZ Royal ត្រូវមានសិទ្ធិក្នុងការផ្ទេរគណនីដែលប្រើរូបិយប័ណ្ណដុល្លាររបស់លោកអ្នកស្របតាមតម្រូវការនោះ។ វិធីសាស្ត្រដែលត្រូវយកមកអនុវត្តក្នុងការប្តូររូបិយប័ណ្ណណាមួយ ទៅជារូបិយប័ណ្ណមួយផ្សេងទៀតនឹងក្លាយជាបែបបទជាគំរូរបស់យើងខ្ញុំសម្រាប់ការប្តូររូបិយប័ណ្ណ។

## 17. ចំនួនទឹកប្រាក់ដែលជំពាក់

លោកអ្នកយល់ព្រមថា ធនាគារ ANZ Royal អាចដកប្រាក់ដោយផ្ទាល់ចេញពីគណនីរបស់លោកអ្នកនូវទឹកប្រាក់ដែលលោកអ្នកបានជំពាក់ធនាគារ ANZ Royal ។

## 18. ការបិទគណនីរបស់លោកអ្នក

លោកអ្នក ឬអ្នកដែលទទួលបានសិទ្ធិពីលោកអ្នកអាចបិទគណនីរបស់លោកអ្នកបានគ្រប់ពេលវេលាទៅតាមសំណើសុំនៅតាមសាខាធនាគារ ANZ Royal របស់លោកអ្នក។

សៀវភៅមូលប្បទានបត្រ ឬកាតអេឡិចត្រូនិកដែលប្រើប្រាស់គណនីរបស់លោកអ្នកនោះត្រូវប្រគល់ជូនធនាគារ ANZ Royal វិញនៅពេលដែលលោកអ្នកបិទគណនីរបស់លោកអ្នក។ ធនាគារ ANZ Royal នឹងទូទាត់ ជាមួយលោកអ្នកនូវទឹកប្រាក់ដែលមានក្នុងគណនី បូកបន្ថែមការប្រាក់ បញ្ញើប្រសិនបើមាន ហើយដកថ្លៃឈ្នួលគណនីដែលគរទុក និងកម្រៃផ្សេងៗសម្រាប់រដ្ឋាភិបាលដែលត្រូវបង់នៅថ្ងៃបិទគណនី។ កម្រៃត្រូវបង់ប្រចាំខែនឹងត្រូវយកមកអនុវត្ត ទោះបីជាគណនីត្រូវបានបើកក្នុងថ្ងៃណាមួយនៃខែ។ រាល់មូលនិធិទាំងឡាយណាដែលមិនទាន់បានផាត់ទាត់រួចនឹងមិនប្រគល់ឱ្យទេដរាបណាមូលនិធិទាំងនោះត្រូវបានផាត់ទាត់សព្វគ្រប់។

គណនីដែលប្រើមូលប្បទានបត្រអាចត្រូវបានបិទ ក្រោយពេលមូលប្បទានបត្រដែលមិនទាន់បានទូទាត់រួចត្រូវបានបង្ហាញ។ ធនាគារ ANZ Royal រក្សាសិទ្ធិក្នុងការទាមទារមកវិញនូវមូលប្បទានបត្រសម្រាប់ការទូទាត់ប្រាក់ក្រោយពេលគណនីបានបិទ។

ប្រសិនបើគណនីរបស់លោកអ្នកមិនទាន់មានទឹកប្រាក់ ឬជិពាក់ប្រាក់ ហើយគ្មានការធ្វើប្រតិបត្តិការ (លើកលែងតែកម្រៃ និងសោហ៊ុយសម្រាប់រដ្ឋាភិបាល) លើសពី 3 ខែ ធនាគារ ANZ Royal អាចបិទគណនីរបស់លោកអ្នក។ ធនាគារ ANZ Royal មានឆន្ទានុសិទ្ធិរបស់ខ្លួនអាចបិទគណនីដោយសារតែមានការប្រព្រឹត្តិដែលមានលក្ខណមិនសមស្រប ឬតម្រូវឱ្យធ្វើបែបនោះតាមច្បាប់ ឬដោយសារតែមូលហេតុអ្វីផ្សេងទៀតដែលខ្លួនចាត់ទុកថាសមស្រប។ ចំពោះមូលហេតុនេះ ធនាគារ ANZ Royal នឹងជូនព័ត៌មានដល់លោកអ្នកជាលាយល័ក្ខអក្សរតាមអាសយដ្ឋាន ដូចដែលបានបង្ហាញក្នុងឯកសារ ហើយនឹងចេញមូលប្បទានបត្រសម្រាប់ទឹកប្រាក់សរុប ដែលនៅសល់ក្នុងគណនីដែលលោកអ្នកអាចយកបាននៅតាមសាខាដែលបានរក្សាទុកគណនីរបស់លោកអ្នក។

## 19. លក្ខខណ្ឌច្បាស់លាស់សម្រាប់រយះពេលនៃការតម្កល់ប្រាក់

គណនីសន្សំមានកាលកំណត់អាចអនុញ្ញាតឱ្យដកប្រាក់មុនថ្ងៃកំណត់បានលុះត្រាតែមានការព្រមព្រៀងច្បាស់លាស់ជាមួយការឯកភាពពីធនាគារ ANZ Royal ។ ប្រសិនបើធនាគារយល់ព្រមឱ្យដកប្រាក់មុនថ្ងៃកំណត់នោះ ប្រាក់កម្រៃត្រូវបានគិត ហើយធនាគារមានសិទ្ធិកាត់យកការប្រាក់មិនតិចជាង 50 ភាគរយអាស្រ័យទៅតាមថ្ងៃដែលប្រគល់ប្រាក់។

## 20. សេវាកម្មភាគីទី 3

ធនាគារ ANZ Royal នឹងមិនផ្តល់សិទ្ធិ ឬអនុញ្ញាត និងមិនឆ្លើយតប ឬទុកចិត្តចំពោះភាគីទីបីក្នុងការប្រើប្រាស់គណនីនៃធនាគារ ANZ Royal

របស់លោកអ្នកឡើយ (រួមទាំងសេវាកម្មគណនីរួមដែលត្រូវបានផ្តល់ឱ្យដោយវិទ្យាស្ថានហិរញ្ញវត្ថុដទៃទៀត)។

## 21. សំណង

លោកអ្នកយល់ព្រមថាសងធនាគារ ANZ Royal ចំពោះការខាតបង់ការចំណាយ ឬការខូតខាតផ្សេងៗដែលធនាគារ ANZ Royal បានជួបប្រទះដោយសារតែការទាមទារតម្រូវការ ឬវិធានការណាមួយដែលបានធ្វើចំពោះធនាគារ ANZ Royal ដែលកើតឡើងដោយផ្ទាល់ ឬដោយប្រយោលដោយតែលោកអ្នក៖

ក- មិនបានបំពេញតាមកាតព្វកិច្ចរបស់លោកអ្នកស្របតាមលក្ខខ័ណ្ឌទាំងនេះ ឬ

ខ- បានប្រព្រឹត្តដោយភាពធ្វេសប្រហែស ឬដោយក្លែងបន្លំទាក់ទងនឹងគណនីរបស់លោកអ្នកយល់ព្រមថាសងធនាគារ ANZ Royal នូវរាល់ថ្លៃឈ្នួល កម្រៃ ឬតម្លៃផ្សេងៗ ដែលកើតមានចំពោះធនាគារ ANZ Royal ដែលទាក់ទងនឹងគណនីនេះ។

## 22. សេចក្តីជូនដំណឹង និងការព្រមព្រៀង

ដរាបណាធនាគារ ANZ Royal មិនបានព្រមព្រៀងអ្វីផ្សេងពីនេះទេ៖

ក- រាល់សេចក្តីជូនដំណឹងធ្វើឡើងដោយលោកអ្នក ឬទាក់ទងនឹងគណនីរបស់លោកអ្នក អាចមានសុពលភាពលុះត្រាធ្វើឡើងជាលាយលក្ខអក្សរ និងបញ្ជូនដល់ធនាគារ ANZ Royal

ខ- រាល់ការព្រមព្រៀងទាំងឡាយរវាងធនាគារ ANZ Royal និងលោកអ្នកទាក់ទងនឹងលក្ខខ័ណ្ឌទាំងនេះត្រូវសរសេរជាលាយលក្ខអក្សរឱ្យមានសុពលភាព។

## 23. លក្ខខ័ណ្ឌនៃការប្រើប្រាស់សេវាកម្មធនាគារអេឡិចត្រូនិក

*លក្ខខ័ណ្ឌនេះត្រូវអនុវត្តចំពោះប្រតិបត្តិការអេឡិចត្រូនិកទាំងអស់*

## 23.1 ប្រតិបត្តិការនៅបរទេស

*សេវាកម្ម MAESTRO និង CIRRUS*

MAESTRO និង CIRRUS គឺជាសេវាកម្មផ្ទេរប្រាក់អេឡិចត្រូនិកនៅចំណុចប្រតិបត្តិការលក់ (EFITPOS) និងជាបណ្តាញម៉ាស៊ីនដកប្រាក់ស្វ័យប្រវត្តិ (ATM) ដែលជួយឱ្យអតិថិជនអាចប្រើប្រាស់សាច់ប្រាក់នៅក្នុងគណនីធនាគារ ANZ Royal របស់ខ្លួនតាមរយៈកាតឥណពន្ធធនាគារ ANZ Royal នៅពេលកំពុងស្នាក់នៅបរទេស។

*ថ្លៃឈ្នួល និងថ្លៃសេវាកម្ម MAESTO និង CIRRUS*

ថ្លៃឈ្នួល និងថ្លៃសេវាកម្មប្រតិបត្តិការ និងការប្តូរប្រាក់ត្រូវបានគិតសម្រាប់ការប្រើប្រាស់ម៉ាស៊ីន ATM របស់ CIRRUS និងសេវាកម្មផ្ទេរប្រាក់អេឡិចត្រូនិកនៅចំណុចប្រតិបត្តិការលក់ MAESTRO EF POS នៅបរទេស។ ប្រសិនបើចំនួនទឹកប្រាក់នៃប្រតិបត្តិការមានចំនួនលើសសមតុល្យដែលមាន (គិតទាំងចំនួនទឹកប្រាក់កំណត់លើសសមតុល្យណាមួយដែលបានព្រមព្រៀង) នោះប្រតិបត្តិការនឹងត្រូវបដិសេធ ហើយក៏ពុំមានការគិតថ្លៃសេវាកម្មណាមួយផងដែរ។ នៅតាមម៉ាស៊ីន ATM នានានៅបរទេស លោកអ្នកពុំអាចប្រើកាតឥណពន្ធធនាគារ ANZ Royal ដើម្បីដាក់ប្រាក់បញ្ញើ ឬផ្ទេរប្រាក់ទៅគណនីនៅក្នុងបណ្តាញឡើយ។

រាល់ប្រតិបត្តិការទាំងអស់នឹងត្រូវបានដំណើរការតាមរយៈកាតអន្តរជាតិ Master (MasterCard) ដោយមានអត្រាប្តូរប្រាក់កំណត់មួយដែលអនុលោមទៅតាមនីតិវិធីរបស់ខ្លួន។ ប្រតិបត្តិការជារូបិយប័ណ្ណផ្សេងក្រៅពីប្រាក់ដុល្លារអាមេរិកនឹងត្រូវប្តូរមកជាប្រាក់ដុល្លារអាមេរិកជាមុនសិននៅក្នុងថ្ងៃដែលប្រតិបត្តិការនោះបានដំណើរការដោយ MasterCard ដោយអនុលោមទៅតាមនីតិវិធីប្តូរប្រាក់របស់ខ្លួន។

នីតិវិធីប្តូរប្រាក់របស់ MasterCard រួមទាំងការប្រើប្រាស់អត្រាប្តូរប្រាក់ត្រូវបានកំណត់ដោយ MasterCard ដែលប្រើអត្រាប្តូរប្រាក់ផ្លូវការរបស់

រដ្ឋាភិបាល ឬអត្រាប្តូរប្រាក់របស់អ្នកលក់ដុំ ហើយអត្រានេះនឹងត្រូវប្រើដើម្បីប្តូររូបិយប័ណ្ណ នៅថ្ងៃដែលប្រតិបត្តិការត្រូវបានដំណើរការដោយប្រព័ន្ធ។ អត្រាប្តូរប្រាក់នេះអាចមានភាពខុសគ្នាពីអត្រាប្តូរប្រាក់នៅថ្ងៃធ្វើប្រតិបត្តិការ ឬក៏អត្រាប្តូរប្រាក់នៅថ្ងៃដែលបានកត់ត្រាទៅក្នុងគណនីរបស់លោកអ្នកនៅធនាគារ ANZ Royal ។

ថ្លៃឈ្នួលខាងក្រោមនេះនឹងត្រូវបានគិតពីធនាគារ ANZ Royal ដោយ MasterCard ប្រសិនបើលោកអ្នកធ្វើប្រតិបត្តិការកាតឥណពន្ធធនាគារ ANZ Royal នៅពេលកំពុងស្នាក់នៅបរទេស៖

- ថ្លៃសេវាកម្មវាយតម្លៃការប្តូរប្រាក់ (0,2% នៃតម្លៃសរុបប្រតិបត្តិការ) សម្រាប់សេវាកម្មប្តូរប្រាក់
- ថ្លៃសេវាកម្មវាយតម្លៃអ្នកចេញកាតឆ្លងប្រទេស (0,8% នៃតម្លៃសរុបប្រតិបត្តិការ) សម្រាប់ប្រតិបត្តិការឆ្លងដែននានា។ ប្រតិបត្តិការឆ្លងដែនគឺជាប្រតិបត្តិការដែលធ្វើឡើងនៅក្រៅប្រទេសដែលអ្នកប្រើប្រាស់កាតបានបើកគណនី។

តាមរយៈការគិតថ្លៃសេវាកម្មខាងលើនេះ ធនាគារ ANZ Royal នឹងគិតប្រាក់ពីលោកអ្នកសម្រាប់ថ្លៃសេវាកម្មវាយតម្លៃការប្តូរប្រាក់ (0,2% នៃតម្លៃប្រតិបត្តិការ និងថ្លៃសេវាកម្មវាយតម្លៃអ្នកចេញកាតឆ្លងដែន 0.8% នៃតម្លៃប្រតិបត្តិការ។ ថ្លៃសេវាកម្មទាំងនេះនឹងគិតបញ្ចូលរួមគ្នានៅក្នុងតម្លៃសរុបនៃប្រតិបត្តិការដោយមិនមានបញ្ជាក់ដាច់ដោយឡែកនៅក្នុងរបាយការណ៍គណនីឡើយ។
ប្រសិនបើរូបិយប័ណ្ណដែលលោកអ្នកធ្វើប្រតិបត្តិការតាមរយៈកាតឥណពន្ធធនាគារ ANZ Royal នៅពេលកំពុងស្នាក់នៅបរទេស ដូចគ្នានឹងរូបិយប័ណ្ណនៃគណនីរបស់លោកអ្នកនៅធនាគារ ANZ Royal នោះធនាគារ ANZ Royal នឹងមិនគិតថ្លៃសេវាកម្មប្តូរប្រាក់ពីលោកអ្នកទេ ប៉ុន្តែថ្លៃសេវាកម្មវាយតម្លៃអ្នកចេញកាតឆ្លងដែននៅតែគិតពីលោកអ្នកដដែល។

## 23.2. ចំនួនកំណត់នៃការដកប្រាក់ប្រចាំថ្ងៃ

លើកលែងតែលោកអ្នកបានស្នើសុំធនាគារ ANZ Royal ដើម្បីបន្ថែម ឬបន្ថយចំនួនកំណត់នៃទឹកប្រាក់របស់លោកអ្នក នោះចំនួនកំណត់ទឹកប្រាក់ប្រចាំថ្ងៃដែលអ្នកអាចប្រើម៉ាស៊ីន ATM និងសេវាកម្មផ្ទេរប្រាក់នៅចំណុចប្រតិបត្តិការលក់ (EFTPOS) សម្រាប់កាតឥណពន្ធអន្តរជាតិមានចំនួន 1.000 ដុល្លារ និងសម្រាប់កាតឥណពន្ធ Premier មានចំនួន 2.000 ដុល្លារ។ នេះមានន័យថាលោកអ្នកអាចប្រើកាតឥណពន្ធអន្តរជាតិរបស់លោកអ្នកដកប្រាក់សរុបបានចំនួន 1.000 ដុល្លារ ឬក៏ប្រើកាតឥណពន្ធ Premier របស់លោកអ្នកដកប្រាក់សរុបបានចំនួន 2.000 ដុល្លារក្នុងមួយថ្ងៃពីបណ្ណាញគណនីនានារបស់កាតដែលមានសមតុល្យទឹកប្រាក់។

## 23.3. សុពលភាព និង កាលបរិច្ឆេទផុតកំណត់របស់កាតឥណពន្ធ

ទោះក្នុងកាលៈទេសៈណាក៏ដោយកាតឥណពន្ធធនាគារ ANZ Royal របស់លោកអ្នកគឺជាកម្មសិទ្ធិរបស់ធនាគារ ANZ Royal ជានិច្ច។

កាតឥណពន្ធធនាគារ ANZ Royal ត្រូវតែចុះហត្ថលេខាភ្លាមៗដោយអ្នកប្រើប្រាស់កាតដែលធនាគារផ្តល់ជូន ហើយកាតនេះអាចប្រើប្រាស់បានតែចន្លោះ "មានសុពលភាពព" ដល់ "រហូតដល់" ដែលមានបញ្ជាក់នៅលើកាត។ ដើម្បីធានាសុវត្ថិភាព លោកអ្នកត្រូវកាច់កាតជាពីរតាមខ្សែអង្កត់ទ្រូងភ្លាមនៅពេលកាតឥណពន្ធរបស់លោកអ្នកអស់សុពលភាព។

## 23.4. ការលុបចោលសេវាកម្មកាតឥណពន្ធ ឬសេវាកម្មអេឡិចត្រូនិក Access (Electronic Access)

ធនាគារ ANZ Royal អាចលុបចោលសេវាកម្មកាតឥណពន្ធ ឬសេវាកម្មអេឡិចត្រូនិក Access (Electronic Access) ដោយ៖

ក- មិនចាំបាច់ជូនដំណឹងជាមុនប្រសិនបើ៖

- ធនាគារ ANZ Royal ជឿជាក់ថាការប្រើកាតឥណពន្ធធនាគារ ANZ Royal ឬសេវាកម្មអេឡិចត្រូនិក Access អាចបណ្តាលឱ្យមានការខាតបង់ដល់ម្ចាស់គណនី ឬធនាគារ ANZ Royal
- នៅក្នុងករណីនេះ កាតនឹងត្រូវបានបដិសេធដោយស្វ័យប្រវត្តិ
- រាល់បណ្តាញគណនីនានាដែលកាតអាចប្រើប្រាស់បាននឹងត្រូវបិទ
- ធនាគារ ANZ Royal មានការសង្ស័យថាលោកអ្នកមានការពាក់ព័ន្ធនឹងការក្លែងបន្លំ ឬក៏មានការពាក់ព័ន្ធនឹងការប្រព្រឹត្តិមិនត្រឹមត្រូវណាមួយ ឬ

ខ- ផ្តល់ជូនលោកអ្នកនូវលិខិតជូនដំណឹងលើសពីមួយខែ។

ម្ចាស់គណនីអាចលុបចោលការប្រើប្រាស់កាតឥណពន្ធធនាគារ ANZ Royal បានគ្រប់ពេលដោយគ្រាន់តែផ្ញើលិខិតជូនដំណឹង ឬក៏ទូរស័ព្ទមកធនាគារ ANZ Royal តាមរយៈលេខដែលមានបញ្ជាក់នៅទំព័រខាងក្រោយនៃកូនសៀវភៅនេះ។

## 23.5. ការបញ្ឈប់ដំណើរការរបស់សេវាកម្មអេឡិចត្រូនិក Access

ធនាគារ ANZ Royal អាចបញ្ឈប់ដំណើរការសេវាកម្មអេឡិចត្រូនិក Access ពីគណនីណាមួយតាមរយៈម៉ាស៊ីនអេឡិចត្រូនិកដោយមិនចាំបាច់ជូនដំណឹងជាមុនប្រសិនបើ៖

- ឧបករណ៍អេឡិចត្រូនិកមិនដំណើរការ ឬក៏មិនអាចប្រើប្រាស់បាន
- ពាណិជ្ជករបដិសេធមិនទទួលយកកាតឥណពន្ធធនាគារ ANZ Royal របស់លោកអ្នក។
- មានគណនីណាមួយត្រូវបានដក ឬនឹងត្រូវដកលើសចំនួនសមតុល្យ ឬក៏ធនាគារ ANZ Royal បានចាត់ទុកថាមិនត្រឹមត្រូវ
- ធនាគារ ANZ Royal ជឿជាក់ថាការប្រើប្រាស់គណនីរបស់លោកអ្នកតាមរយៈម៉ាស៊ីនអេឡិចត្រូនិកអាចមានការខាតបង់ដល់ម្ចាស់គណនី ឬធនាគារ ANZ Royal
- ធនាគារ ANZ Royal ជឿជាក់ថាគុណភាព ឬសុវត្ថិភាពនៃដំណើរការអេឡិចត្រូនិក ឬក៏ប្រព័ន្ធដំណើរការធនាគារ ANZ Royal មិន

អាចបំពេញតាមតម្រូវការបាន ឬ

- ធនាគារ ANZ Royal មានការសង្ស័យថាលោកអ្នកមានការពាក់ព័ន្ធនឹងការក្លែងបន្លំ ឬក៏មានការពាក់ព័ន្ធនឹងការប្រព្រឹត្តិមិនត្រឹមត្រូវណាមួយ
- មានការហាមឃាត់ដោយច្បាប់។

គ្រប់ពេលទាំងអស់ ធនាគារ ANZ Royal រក្សាសិទ្ធិផ្លាស់ប្តូរប្រភេទគណនីណាមួយ ដែលអាចត្រូវបានប្រើ ឬប្រភេទប្រតិបត្តិការអេឡិចត្រូនិកណាមួយដែលធ្វើឡើងតាមរយៈម៉ាស៊ីនអេឡិចត្រូនិក។

## 23.6. ការផ្លាស់ប្តូរប្រតិបត្តិការតាមរយៈម៉ាស៊ីនអេឡិចត្រូនិក

លោកអ្នកមិនអាចផ្លាស់ប្តូរ កែប្រែ ឬលុបចោលប្រតិបត្តិការណាមួយដែលលោកអ្នកបានធ្វើឡើងតាមរយៈម៉ាស៊ីនអេឡិចត្រូនិក។

## 23.7. ការចេញរបាយការណ៍ប្រតិបត្តិការ

ពេលលោកអ្នកធ្វើប្រតិបត្តិការតាមរយៈម៉ាស៊ីនអេឡិចត្រូនិក លោកអ្នកនឹងទទួលបានរបាយការណ៍បញ្ជាក់ពីប្រតិបត្តិការរបស់លោកអ្នក។ លោកអ្នកត្រូវពិនិត្យមើលរបាយការណ៍ឱ្យបានត្រឹមត្រូវ។ លោកអ្នកគួររក្សារបាយការណ៍នេះទុកដើម្បីផ្ទៀងផ្ទាត់ និងជួយលោកអ្នកក្នុងពិនិត្យមើលរបាយការណ៍កែសម្រួលរបស់គណនីលោកអ្នក។

## 23.8. ចំនួនទឹកប្រាក់កំណត់របស់ប្រតិបត្តិការ

ធនាគារ ANZ Royal អាចផ្លាស់ប្តូរ ឬកម្រិតចំនួនទឹកប្រាក់កំណត់ដែលលោកអ្នកអាចប្រើបានតាមរយៈម៉ាស៊ីនអេឡិចត្រូនិក ហើយចំពោះប្រតិបត្តិការណាដែលធ្វើឡើងក្រោយរយៈពេលកំណត់ លោកអ្នកត្រូវប្រើកាតឥណពន្ធធនាគារ ANZ Royal និងលេខកូដសម្ងាត់ផ្ទាល់ខ្លួន។ ពាណិជ្ជករ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀតអាចកម្រិតចំនួនទឹកប្រាក់កំណត់នៃប្រតិបត្តិការនីមួយៗបានផងដែរ។

## 23.9. ការទទួលខុសត្រូវរបស់លោកអ្នកចំពោះកាតឥណពន្ធ និងលេខកូដសម្ងាត់របស់លោកអ្នក

សុវត្ថិភាពកាតឥណពន្ធធនាគារ ANZ Royal និងលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកមានសារៈសំខាន់បំផុត។ ប្រសិនបើលោកអ្នកមិនអាចរក្សាសុវត្ថិភាពកាតឥណពន្ធ និងលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកបានទេ លោកអ្នកប្រហែលជាធ្វើឱ្យបំណុលរបស់ម្ចាស់គណនីកើនឡើងដោយសារតែមានការប្រើប្រាស់ដែលគ្មានអនុញ្ញាត។

*សុវត្ថិភាពកាតឥណពន្ធ លោកអ្នកត្រូវតែ៖*

- ចុះហត្ថលេខានៅខាងក្រោយកាតឥណពន្ធធនាគារ ANZ Royal ភ្លាមនៅពេលលោកអ្នកបានទទួលកាត
- កាច់កាតជាពីរតាមខ្សែអង្កត់ទ្រូងភ្លាមនៅពេលកាតអស់សុពលភាព
- មិនត្រូវអនុញ្ញាតឱ្យអ្នកផ្សេងប្រើកាតឥណពន្ធធនាគារ ANZ Royal របស់លោកអ្នកឡើយ
- ត្រូវរក្សាកាតឥណពន្ធធនាគារ ANZ Royal របស់លោកអ្នកបានល្អកុំឱ្យបាត់ ឬចោរលួច។

*សុវត្ថិភាពលេខកូដសម្ងាត់ផ្ទាល់ខ្លួន លោកអ្នកត្រូវតែ៖*

- មិនត្រូវរក្សាទុកកាត និងលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកជាមួយគ្នាឡើយ
- កុំឱ្យអ្នកណាម្នាក់ដឹងលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក
- ព្យាយាមចងចាំលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នកជាជាងកត់ទុកនៅកន្លែងណាមួយ
- មិនត្រូវជ្រើសរើសលេខកូដសម្ងាត់ផ្ទាល់ខ្លួនណាដែលស្រួលចាំឡើយ ឧទាហរណ៍ លេខ ឬអក្សរដូចៗគ្នា និង
- មិនត្រូវជ្រើសរើសលេខកូដសម្ងាត់ផ្ទាល់ខ្លួនដែលងាយស្រួលស្មានឧទាហរណ៍ ថ្ងៃខែឆ្នាំកំណើត លេខរថយន្ត លេខទូរស័ព្ទ ឬឈ្មោះរបស់លោកអ្នកឡើយ។

នៅពេលកាតឥណពន្ធធនាគារ ANZ Royal ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក ត្រូវបានចោរលួច ឬបាត់ប្រសិនបើកាតឥណពន្ធធនាគារ ANZ Royal ឬលេខកូដសម្ងាត់ផ្ទាល់ខ្លួនត្រូវបានចោរលួច ឬបាត់ ឬក៏មាននរណាម្នាក់បានដឹងលេខកូដសម្ងាត់ផ្ទាល់ខ្លួនរបស់លោកអ្នក សូមជូនដំណឹងមកធនាគារ ANZ Royal ជាបន្ទាន់។ វិធីដែលល្អបំផុត សូមរាយការណ៍មកបុគ្គលិកនៅសាខាធនាគារ ANZ Royal ណាមួយ ឬទូរស័ព្ទមកយើងខ្ញុំតាមរយៈលេខទូរស័ព្ទដែលមានបញ្ជាក់នៅទំព័រខាងក្រោយនៃកូនសៀវភៅនេះ។

## *23.10. លក្ខណៈទូទៅ*

ធនាគារ ANZ Royal មិនទទួលខុសត្រូវចំពោះការបដិសេធណាមួយរបស់ពាណិជ្ជករ ដែលមិនទទួលយកការទូទាត់តាមរយៈប្រតិបត្តិការអេឡិចត្រូនិកឡើយ ហើយយោងតាមការអនុញ្ញាតរបស់ច្បាប់ធនាគារ ANZ Royal មិនទទួលខុសត្រូវចំពោះទំនិញ និងសេវាកម្មដែលផ្តល់ឱ្យដោយពាណិជ្ជករ។

*លោកអ្នកទទួលស្គាល់ថា៖*

- គ្រប់ម៉ាស៊ីនអេឡិចត្រូនិកទាំងអស់ដែលអាចដកប្រាក់បានមិនមែនសុទ្ធតែមានប្រាក់គ្រប់ពេលវេលានោះទេ
- ហានិភ័យបណ្តាលមកពីការដកប្រាក់ណាមួយតាមរយៈម៉ាស៊ីនអេឡិចត្រូនិកគឺជាការទទួលខុសត្រូវរបស់លោកអ្នក ហើយ
- គ្រប់ម៉ាស៊ីនអេឡិចត្រូនិកទាំងអស់មិនអាចដាក់ប្រាក់បញ្ញើឡើយ។

This document contains terms and conditions for the following:

Access Account

Premier Account

Saving Account

Cash Management Account – (Personal)

ANZ Royal Bank @ work Access Account

Business Cheque Account

Business Cheque Account (Bearing Interest)

Cash Management Account – (Business)

Foreign Currency Account

Term Deposit Account

This document must be read in conjunction with the ANZ Royal Bank Fees and Charges' brochure. Together they form the terms and conditions which apply to the above products.

## *1. References to ANZ Royal Bank*

In these terms,
'ANZ Royal Bank' means ANZ Royal Bank (Cambodia) Ltd.
'account' means an account to which these terms apply, as listed on the front cover of this booklet.

'account holder' means the person or persons in whose name the account has been opened and who is responsible for the account under the relevant account signature mandate. If there is more than one account holder, then 'account holder' means all of them and each of them individually.

'ANZR Debit Card' means the International Debit Card or the Premier Debit Card issued by ANZ Royal Bank to you which can be used to operate an ANZ Royal Bank account at an electronic terminal in Cambodia and/or overseas.

## *2. Application of these terms*

These terms will apply for each account that you open with ANZ Royal Bank, immediately after that account is opened. They apply to you and also your legal successor(s) and/or legally recognized heir(s).

These terms operate in conjunction with other terms and conditions applicable to particular transactions or services in relation to your account ("Specific Terms"). Unless otherwise specifically stated to the contrary in the Specific Terms, to the extent that there is any inconsistency between these terms and the Specific Terms, these terms will apply.

These terms may be amended from time to time by agreement with ANZ Royal Bank or by notice given by ANZ Royal Bank under clause 8.

## *3. Authority for Account Operation*

